ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០៤២-សរ.១៧អអក

ភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងអាជ្ញាបណ្ណរបស់ក្រុមហ៊ុន ហាស្សាន់ (ខេមបូឌា) ឌីវិឡុបមិន លីមីធីត សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅក្នុងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារថ្នាក់ផ្កាយ៥ អគារខុនដូ និងកន្លែងកំសាន្ត ដែលស្ថិតនៅអគារលេខ ១១៦ ដេ ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឲ្យបានជ្រាបថា អនុវត្តតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុន ហាស្សាន់ (ខេមបូឌា) ឌីវិឡុបមិន លីមីធីត ដែលមានប្រកាសក្រសួងរ៉ែ និងថាមពល សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅក្នុងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារថ្នាក់ផ្កាយ៥ អគារខុនដូ និងកន្លែងកំសាន្ត ដែលស្ថិតនៅអគារលេខ ១១៦ ដេ ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ តាមសំណើសុំរបស់ក្រុមហ៊ុន ហាស្សាន់ (ខេមបូឌា) ឌីវិឡុបមិន លីមីធីត ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការចេញអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណនៅ..................................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះសូមសាធារណជនរស់នៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុន ហាស្សាន់ (ខេមបូឌា) ឌីវិឡុបមិន លីមីធីត អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **" អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ "** ។៚

អាជ្ញាធរអគ្គិសនីកម្ពុជា

ប្រធាន

បណ្ឌិត.ធី នរិន្ទ្រ

អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាបណ្ណចែកចាយ

## សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅក្នុងតំបន់មជ្ឈមណ្ឌលពាណិជ្ជកម្ម សណ្ឋាគារថ្នាក់ផ្កាយ៥ អាគារខុនដូ និងកន្លែងកំសាន្ត ដែលស្ថិតនៅអគារលេខ ១១៦ ដេ ផ្លូវសហព័ន្ធរុស្សី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

# DISTRIBUTION LICENSE

## FOR PROVIDING ELECTRIC POWER DISTRIBUTION SERVICE AT BUSINESS CENTER, FIVE STAR HOTEL, CONDOMINIUM AND ENTERTAINMENT LOCATED AT #116D, RUSSIAN FEDERATION BLVD, SANGKAT SRACH CHORK, KHAN DAUN PENH, PHNOM PENH CITY

**ក្រុមហ៊ុន ហាសា្សន់ (ខេមបូឌា) ឌីវិឡុបមិន លីមីធីត**

**HASSAN (CAMBODIA) DEVELOPMENT CO., LTD**

ថ្ងៃទី ខែ ឆ្នាំ២០១៧

..., 2017

# ផ្នែកទី១
# សេចក្ដីសម្រេចផ្ដល់សិទ្ធិឲ្យធ្វើសេវាកម្ម

## PART I

## DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE